# ខ្មែរប៉ុស្តិ៍
ឆ្នេរខាងកើត
THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Cell : (267) 253-3947
VOLUME 04 ISSUE 54 February 26th - March 11th 2010


# ភាសា (CASA) ស្វែងរកទីបញ្ចប់វិបត្តិ

ដោយ : ពិន សំខុន



*ហ្វីឡាដែលហ្វៀ* : នៅទីស្នាក់ការសមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង ស្ថិតផ្លូវលេខ៧ខាងត្បូង នាព្រឹកថ្ងៃអាទិត្យ ទី១៤ កុម្ភៈ មានភាពអ៊ូអរខុសប្រក្រតី ដោយសមាជិកសមាគមខ្មែរ ប្រមាណជាង៣០នាក់ បានប្រមូលគ្នាមកជួបជុំដោះស្រាយវិបត្តិ ដែលបានធ្វើឱ្យសមាគមនេះ គាំងដំណើរការប្រមាណជាមួយឆ្នាំមកហើយ ។ ភាពមិនប្រក្រតីមួយទៀត គឺព្រិលបានធ្លាក់គរកំពស់ប្រមាណ ១ ម៉ែត្រ បានរំខានដល់ការធ្វើដំណើរមកចូលរួមប្រជុំបន្ថែមដោយទ្វារបន្ទប់ប្រជុំបានត្រូវជាប់សោរ មិនអាចចូលបានត្រូវទៅអញ្ជើញក្រុមប៉ូលិសសន្តិសុខក្រុងមកជាសាក្សីនៃការគាស់ទ្វារចូលប្រជុំក្នុងទីស្នាក់ការដ៏ត្រជាក់ស្ទើរធ្វើឱ្យគាំងបេះដូង ។



នៅក្នុងបន្ទប់ប្រជុំដ៏តូចចង្អៀតសម្រាប់មនុស្សប្រមាណ ៣០នាក់ គ្មានអគ្គីសនី គ្មានម៉ាស៊ីនកំដៅ បន្ទប់គ្មានទឹកតែក្តៅ ឬទឹកត្រជាក់ ដែលតែងតែមានសម្រាប់ទទួលភ្ញៀវ នៅម៉ោង១១ព្រឹកថ្ងៃអាទិត្យដ៏កំសត់នោះ ជិន វុត្ថា បានបើកអង្គប្រជុំក្នុងនាមជាប្រធានស្តីទីជំនួសឱ្យ សារិន ជូ ដែលជាប្រធានសមាគមព្រឹទ្ធាចារ្យ បានលាលែងដោយសារជម្ងឺធ្ងន់ធ្ងរ មានវត្តមាននៅទីនោះដែរ ។ គោលដៅតែមួយដែល ជិន វុត្ថា បានថ្លែងប្រាប់ទៅអង្គប្រជុំ គឺទទួលតំណែងក្នុងនាមជាអ្នកបច្ចេកទេស ដើម្បីដឹកនាំឱ្យមានការជ្រើសរើសប្រធានសមាគមថ្មី ដើម្បីកាន់តំណែងបន្តពីគណៈកម្មាធិការចាស់នៅពេលនេះ ឬពេលឆាប់ៗខាងមុខ ហើយដឹកនាំដំណើរ "ភាសា" (សមាគមព្រឹទ្ធាចារ្យខ្មែរ) ឱ្យមានដំណើរការប្រក្រតីឡើងវិញ ទៅតាមសំណូមពរដែលវាគ្មិនថ្ងៃនេះបានស្នើមក ។

វត្តមាននៃកងប៉ូលីសក្រុង នាពេលនោះ គឺសម្រាប់ធានាសុវត្ថិភាពនៃអង្គប្រជុំផង ហើយនិងបញ្ជាក់ពីភាពស្របច្បាប់នៃក្រុមអ្នកបើកអង្គប្រជុំនៅទីស្នាក់ការផ្លូវលេខ៧ខាងត្បូងថែមទៀតផង ។ ខ្មែរប៉ុស្តិ៍ បានទទួលចម្លើយពីកងប៉ូលីស ឈ្មោះ Tim (ធីម) នៅទីនោះថា "ការបើកទ្វារទីស្នាក់ការ (តទៅទំព័រទី ១២)

# សាលាឧទ្ធរណ៍ក្រុងប៉ារីសបើកសំណុំរឿងខ្មែរ


លោកស្រី ប៉ុលីយ៉ុង អ៊ុង

**ក្រុងប៉ារីស :** សាលាឧទ្ធរណ៍ក្រុងប៉ារីស បានបើកសំណុំរឿងឡើងវិញ កាលពីថ្ងៃទី២៦ ខែមករា នេះ ករណីអតីតលោកប្រធានរដ្ឋសភាខ្មែរ គឺលោក អ៊ុង ប៊ុនហោ ក្នុងបណ្តឹងរបស់ភរិយាលោក ដែលទាមទាររកយុត្តិធម៌ថា "លោកអគ្គកុងស៊ុលបារាំង ឈ្មោះ ហ្សង់ ឌឿរ៉ាក់ បានប្រគល់ប្តីលោកស្រី រួមជាមួយមន្ត្រីធំៗមួយចំនួនទៀត ដែលមកសុំជ្រកកោននៅស្ថានទូតបារាំង ឱ្យទៅអាជ្ញាធរខ្មែរក្រហម នៅទីក្រុងភ្នំពេញ កាលពីឆ្នាំ១៩៧៥ ពេលដែលក្រុមខ្មែរក្រហមឈ្នះសង្គ្រាម ដោយពុំមានកិច្ចការពារ" ។


លោក អ៊ុង ប៊ុនហោ ពេលបង្ខំខ្លួនឱ្យចេញពីស្ថានទូតបារាំង

បណ្តឹងដោយមិនចំពោះមុខស្តីអំពីឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិរបស់ក្រុងខ្មែរក្រហម នាចន្លោះ ឆ្នាំ១៩៧៥ ដល់ ១៩៧៩ និងស្តីពីការចាប់ឃាត់ខ្លួន, ការសម្លាប់មនុស្ស និងអំពើឃោរឃៅព្រៃផ្សៃ..." កាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ នៅក្រុង "ក្រេតេយ" ជាយក្រុងប៉ារីស បានត្រូវសាលាក្តីនោះ ទាត់ចោលដោយគ្មានសមត្ថភាពម្តងហើយ ។ តែនៅដើមឆ្នាំ ២០០៩ នេះ សាលាឧទ្ធរណ៍ក្រុងប៉ារីស បន្ទាប់ពីទទួល បណ្តឹងសុំឱ្យសាលាក្តីនេះទទួលសមត្ថភាពក្នុងរឿងក្តីនេះ បានវិច្ឆ័យថា "ទទួលបាន និងមានបុព្វហេតុគ្រប់គ្រាន់" ។ លោកស្រីមេធាវី បូ ឌូវ៉ាំង បានថ្លែង "រីករាយពីជោគជ័យថ្មីទទួលបានដោយលំបាក..." នឹងបន្តជួយកូនក្តីលោកស្រី អ៊ុង ប៊ុនហោ ឱ្យរកយុត្តិធម៌ និងស្រាវជ្រាវការពិតជូនប្តីអ្នកស្រី ជាអតីតប្រធានសភាជាតិខ្មែរបាន ។

លោកស្រី ប៉ុលីយ៉ុង អ៊ុង ភរិយាលោក អ៊ឹងប៊ុនហោ អតីតប្រធានរដ្ឋសភាជាតិ ថ្លែងប្រាប់កាសែត ឡឺម៉ុង ថា "ថ្ងៃដែលក្រុមខ្មែរក្រហមចូលក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកស្រីបានចាកចេញពីកម្ពុជា ទៅដល់ក្រុងប៉ារីសហើយ តែប្តីលោកស្រី ពុំបានចេញទៅជាមួយលោកស្រីទេ ជាមួយនឹងមន្ត្រីជាន់ខ្ពស់ឯទៀត លោក ប៊ុនហោ បានសម្រេចចិត្តចូលទៅជ្រកកោននៅស្ថានទូតបារាំង ដែលលោកគិតថា ជាទីផ្តល់សន្តិសុខប្រសើរ ។ ខ្មែររាប់រយនាក់ បានមកនៅត្រៀមត្រា លើវាលស្មៅនៅបរិវេណស្ថានទូត ដើម្បីគេចពីកណ្តាប់ដៃដ៏ឃោឃៅនៃក្រុមអ្នកបដិវត្តន៍ ។

(តទៅទំព័រទី ១៨)

## មាតិការឿង ទំព័រ


១- សម រង្ស៊ី និងការរិះគន់........................ទំព័រទី០៣
២- សមាគមព្រឹទ្ធាចារ្យខ្មែរ........................ទំព័រទី០៤
៣- PHILLY FOR FAMILY UNITY........................ទំព័រទី០៥
៤- អត្ថបទមនោសញ្ចេតនា និងឆ្លើយតបសំនួរមិត្តអ្នកអាន........ទំព័រទី០៦
៥- The Cambodia Daily........................ទំព័រទី០៨-១៣
៦- ASIAN STUDENTS STAND........................ទំព័រទី០៩
៧-សុខភាព........................ទំព័រទី១១


សូមអញ្ជើញលោកអ្នកអានអត្ថបទជាភាសាអង់គ្លេស នៅទំព័រខាងក្នុង ដែលបានដកស្រង់ និងទទួលការអនុញ្ញាតឱ្យចុះផ្សាយពីសារព័ត៌មាន The Cambodia Daily នៅប្រទេសកម្ពុជា ។




Kavei

ភោជនីយដ្ឋានខ្មែរ

320 OREGON AVENUE . PHILADELPHIA PA 19148 . 215-952-6688



នំបញ្ចុកសម្លខ្មែរ

ទស្សនៈវិស័យ:

# សមាគមព្រឹទ្ធាចារ្យខ្មែរដើបឈររឡើងវិញ?



**ដោយ : ម៉ម យឹន**

**បុព្វហេតុ :**

...ជនភៀសខ្លួនខ្មែរជាច្រើនសែននាក់ បានមានភ័ព្វសំណាងមកកសាងជីវិតថ្មី ក្រោយពីបានត្រូវរងទុក្ខមហាវេទនា ដែលជាសោកនាដកម្មមួយប្រកបដោយការឈឺចាប់ ខ្លោចផ្សា ស្លាប់ ព្រាត់ប្រាស់ក្រុមគ្រួសារ គួរឱ្យអាណោចអាធ័មខ្លាំងណាស់ ។

ជីវិតជនជាតិខ្មែរទូទាំងប្រទេស បានត្រូវទទួលមេរៀនដ៏ជូរចត់ពីរបបកុម្មុយនីស្ត រួចហើយនាំគ្នារត់ចេញចាកមាតុប្រទេស ឱ្យបានមកជួបរបបប្រជាធិបតេយ្យសេរីនិយមវិញ ដោយមានក្តីសង្ឃឹមយ៉ាងមាំថា ខ្លួននឹងបានរស់ដោយសុខសាន្ត មានភាពយុត្តិធម៌ក្នុងសង្គម មានភាពស្រឡាញ់រាប់អានគ្នាមានភាពអាណិតអាសូរជួយសង្គ្រោះគ្នា មានភាពសាមគ្គីសាមគ្គាគ្នាដ៏ជិតស្និទ្ធ ។

ដើម្បីបង្ហាញពីភាពដ៏ល្អខាងលើនេះ ទើបជនជាតិខ្មែរយើង ដែលបានចូលមករស់នៅទីក្រុងហ្វីឡាដែលហ្វីយ៉ា រដ្ឋផែនស៊ីលវេនីញ៉ា បានបង្កើតជាសមាគម ២ ដែលមានឈ្មោះថា :

១- សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វីយ៉ា (Cambodian Association of Greater Philadelphia)

២- សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង (Cambodian-American Seniors Association) CASA ។

សមាគមខ្មែរទាំង ២ បានដំណើរការទៅតាមមុខនាទីក្រោមការគ្រប់គ្រងរបស់គណៈកម្មការក្រុមប្រឹក្សាភិបាលកណ្តាល មានសមាជិកចំនួន១០នាក់កើតចេញមកពីការបោះឆ្នោតជ្រើសរើស ។

ដើម្បីសមាគមព្រឹទ្ធាចារ្យ បានបំពេញសកម្មភាព បំរើ ជួយសម្រួលនូវគ្រប់សេចក្តីត្រូវការជាចាំបាច់របស់ជនចាស់ជរាទាំងស្រីទាំងប្រុសទៅបាន សមាគមបានតម្រូវឱ្យមាននាយកប្រតិបត្តិ១រូប និងបុគ្គលិកមួយចំនួន ជួយធ្វើកិច្ចការសំខាន់ៗ ជាគុណប្រយោជន៍ដល់ជនចាស់ជរាទាំងអស់ ។

នៅក្នុងការគ្រប់គ្រងសមាគមឱ្យបានប្រសិទ្ធិភាព និងដំណើរការល្អប្រពៃទៅបាន ប្រធាន និងអនុប្រធានត្រូវបានលក្ខន្តិកៈសមាគមបញ្ញត្តិឱ្យជ្រើសរើសឱ្យធ្វើការបានក្នុង១អាណត្តិរយៈពេល២ឆ្នាំ ហើយតម្រូវឱ្យមានអាយុចាប់ពី ៥៥ឆ្នាំឡើងទៅ ។

សមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំងនេះ បានដំណើរការជាប្រក្រតីមក អស់រយៈពេលជាច្រើនឆ្នាំ និងមានគណៈកម្មការកណ្តាលគ្រប់គ្រងជាច្រើនអាណត្តិមកហើយដែរ បានប្រព្រឹត្តទៅដ៏ល្អប្រសើរ ធ្វើឱ្យអស់លោកចាស់ជរាទាំងស្រីទាំងប្រុសមានការពេញចិត្ត សប្បាយរីករាយ ដោយសារតែមានជំនួយគ្រប់បែបយ៉ាង ។

ប៉ុន្តែគួរឱ្យសោកស្តាយណាស់ សេចក្តីសង្ឃឹម និងសេចក្តីសប្បាយរីករាយរបស់ជនចាស់ជរា ត្រូវបានបាត់បង់ទៅវិញ ដោយសារតែមានបាតុភាព មិនចុះសម្រុងគ្នារវាងគណៈកម្មការកណ្តាល និងនាយកប្រតិបត្តិ ដែលជាអ្នកគ្រប់គ្រងដឹកនាំនូវគ្រប់សកម្មភាពក្នុងសមាគម ។

ភាពមិនចុះសម្រុងគ្នានេះ ចេះតែកើនឡើងបន្តិចម្តងៗ រហូតមកដល់ឆ្នាំ ២០០៩ ស្រាប់តែលេចចេញឱ្យឃើញភាពជាជម្លោះដ៏ខ្លាំង ពុំអាចរិះរកវិធីណាមួយកែខៃដោះស្រាយបានឡើយ គឺមានវិធីដោះស្រាយតែមួយគត់ថា ត្រូវតែដាក់ពាក្យប្តឹងទៅតុលាការក្រុងឱ្យជួយកាត់សេចក្តីបញ្ចប់ជម្លោះនេះ រួចហើយបង្កើតគណៈកម្មការថ្មីមួយទៀតតែប៉ុណ្ណោះ ។

នៅក្នុងជម្លោះនេះ គូភាគីទាំងពីរ បានប្រឈមមុខនិងសេចក្តីសម្រេចរបស់តុលាការ ហើយម្នាក់ៗសំអាងទៅលើតុលាការដូចគ្នា ដូចជានៅពេលខ្លះគណៈកម្មការបានទៅគាស់ដោះសោរទីស្នាក់ការចោល ហើយដាក់សោរថ្មីកុំឱ្យនាយកប្រតិបត្តិចូលបាន ប៉ុន្តែសោរនោះត្រូវបានគាស់ចោលទៅវិញ ហើយនាយកប្រតិបត្តិដាក់សោរថ្មីឡើងវិញ ។ ដូច្នេះរឿងសោរទ្វារនេះ ត្រូវបានគាស់ដូរជាញឹកញាប់ រហូតដល់នាយកប្រតិបត្តិប្រើសិទ្ធិអំណាចបើកប្រជុំអស់លោកចាស់ៗ ឱ្យមកធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មី ដែលជាការធ្វើខុសពីលក្ខន្តិកៈរបស់សមាគម ។

ដោយសំអាងទៅលើសេចក្តីសម្រេចរបស់តុលាការក្រុង គណៈកម្មការដែលកំពុងគ្រប់គ្រង បានចាត់ការបើកប្រជុំអស់លោកចាស់ៗ ទាំងស្រីទាំងប្រុស កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ ដើម្បីពិភាក្សាគ្នារកដំណោះស្រាយ រៀបចំការបោះឆ្នោត បង្កើតគណៈកម្មការថ្មី ឱ្យបានបំពេញមុខនាទីជាអ្នកគ្រប់គ្រងដល់ជនចាស់ជរាជាថ្មីបន្តទៅទៀត ។

សភាពដ៏ចំឡែកមួយ ដែលគួរឱ្យអាម៉ាស់ គឺការចូលក្នុងទីស្នាក់ការសមាគម ដោយប្រើរបៀបដូចគ្នាជនពាលចូលលួចផ្ទះគេ ដោយវាយបំបែកកញ្ចប់បង្ហួច ក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរសមត្ថកិច្ច ការនេះគួរណាស់តែរៀបចំទុកជាមុន ឱ្យបានរៀបរយជាស្រេច មុនពេលបើកអង្គប្រជុំ ទើបជាការប្រសើរ ។

ក្រោយពីបានស្តាប់ការពន្យល់បំភ្លឺអង្គប្រជុំអំពីឧប្បទ្ទវហេតុដែលកើតឡើងអស់ពេលមួយរយៈ បណ្តាលឱ្យសមាគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំងផ្អាកសកម្មភាពមក លោកប្រធានបណ្តោះអាសន្ន លោកវុត្ថា ជិន បានប្រកាសបើកអង្គប្រជុំ ដោយលើកយកពាក្យ២ម៉ាត់ថា គុណសម្បត្តិ និងគុណវិបត្តិមកសួរថា តើមានន័យដូចម្តេច? សុំឱ្យលោក សំខុន ពិន ជួយពន្យល់ ។

ដោយសារតែពាក្យ២ម៉ាត់នេះហើយ បានជាអង្គប្រជុំត្រូវតែមាននៅថ្ងៃនេះ ហើយសុំឱ្យអង្គប្រជុំជួយផ្តល់យោបល់ រកដំណោះស្រាយបញ្ចប់ភាពអាប់អួរ និងអសកម្មភាពនៃសមាគម រួចហើយបង្កើតបរិយាកាសល្អប្រសើរនៅក្រោមរូបភាពរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការក្រុមប្រឹក្សាភិបាលថ្មីឡើងវិញ ។

កិច្ចពិភាក្សាបានបញ្ចប់ទៅយ៉ាងល្អប្រសើរ ទោះបីមានជនខ្លះបញ្ចេញយោបល់ដោយប្រើពាក្យសំដីហាក់បីដូចជាមានកំហឹងក៏ដោយ ក៏អង្គប្រជុំបានសម្រួលទៅតាមមតិភាគច្រើនដែរ ។ នៅក្នុងរយៈពេលពិភាក្សាគ្នាប្រមាណជិត ២ម៉ោង មានមតិខ្លះបានបង្ហាញពីសេចក្តីព្រួយបារម្ភអំពីការរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីឡើងវិញ ខ្លាចក្រែងមិនបានសមតាមបំណង ដោយសំអាងទៅលើអស់លោកចាស់ៗ នៅក្នុងក្រុងហ្វីឡាដែលហ្វីយ៉ានេះមានចំនួនច្រើនប្រមាណរាប់ពាន់នាក់ ហើយបានមកចូលរួមប្រជុំតែបន្តិចបន្តួច មានន័យថា មានជនចាស់ៗ ដែលមិនពេញចិត្តនឹងការគ្រប់គ្រងពីមុនភាគច្រើន ដូច្នេះវានឹងអាចបណ្តាលឱ្យមានការជ្រើសតាំងគណៈកម្មការថ្មីនេះ ពុំអាចនាំយកប្រធាន និងអនុប្រធានថ្មី មកគ្រប់គ្រងឱ្យបានត្រឹមត្រូវ ហើយនឹងអាចបណ្តាលឱ្យមានវិបត្តិទៅពេលក្រោយទៀត ។

មានន័យម្យ៉ាងទៀតថា សម្លេងនៅក្នុងអង្គប្រជុំភាគច្រើន គឺចេញមកពីក្រុមគណៈកម្មការចាស់ ចំណែកភាគីម្ខាងទៀត ពុំបានចូលរួម ដើម្បីសម្រុះសម្រួលគ្នាឱ្យបានដាច់ជ្រះស្រឡះទេ ដើម្បីឱ្យអង្គប្រជុំងាយស្រួលក្នុងការពិចារណា ស្វែងរកការពិត និងដឹងពីភាពយុត្តិធម៌បានផង ។

ដូច្នេះការបើអង្គប្រជុំថ្ងៃនេះ គឺគ្រាន់តែជាការស្ទង់ស្ទាបដល់ទឹកចិត្ត និងគោលបំណងជនចាស់ៗតែប៉ុណ្ណោះ ដើម្បីឈានទៅដល់ការបោះឆ្នោតក្នុងរយៈពេលជាង ២ខែខាងមុខ ។

អង្គប្រជុំបានសម្រេចបង្កើតគណៈកម្មការរៀបចំការបោះឆ្នោតមួយ ដែលមានសមាជិក សមាជិការចំនួន ៥រូប ឱ្យធ្វើជាអ្នកសម្របសម្រួលឱ្យបានសម្រេចកិច្ចការក្នុងការបង្កើតគណៈកម្មការក្រុមប្រឹក្សាភិបាលកណ្តាលថ្មី និងតែងតាំងនាយកប្រតិបត្តិថ្មី សំរាប់បន្តសកម្មភាព បំរើ ជួយទំនុកបំរុងដល់ជនចាស់ជរាទាំងអស់ ឱ្យបានទទួលភាពកក់ក្តៅ មានសេចក្តីសង្ឃឹម និងសប្បាយរីករាយជាថ្មីឡើងវិញ ។

**សេចក្តីសន្និដ្ឋាន :**

ដោយយោងទៅតាមការមើលឃើញ និងការដឹងជាក់ស្តែងនៅក្នុងសហគមន៍ខ្មែរ ដែលជាសហគមន៍មួយក្នុងចំណោមសហគមន៍ជាច្រើន បានមកនៅក្នុងសហរដ្ឋអាមេរិក ឃើញថា សហគមន៍ខ្មែរមានភាពទន់ខ្សោយច្រើនគួរឱ្យព្រួយបារម្ភ ។

ហេតុការណ៍បានកើតឡើងកន្លងមក បានបង្ហាញពីភាពខ្វះធម៌សាមគ្គី ខ្វះភាពស្រឡាញ់រាប់អានគ្នា ខ្វះភាពជួយសង្គ្រោះគ្នា ខ្វះភាពស្មោះត្រង់គ្នានិងគ្នា ខ្វះភាពយោគយល់ អធ្យាស្រ័យរវាងគ្នានិងគ្នា ជាពិសេសខ្វះការលើកតំកើងកិត្តិយស និងលើកទឹកចិត្តគ្នា ក្នុងនាមជាជាតិសាសន៍ដូចគ្នា ។

ភាពនៃកង្វះខាងលើនេះហើយ បានបង្កើតឱ្យមានជម្លោះទាស់ទែងគ្នា នៅក្នុងសហគមន៍ខ្មែរគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ក្នុងវត្តអារាម ក្នុងសង្គមគ្រួសារ និងក្នុងអង្គការនានារបស់ខ្មែរ រហូតធ្វើឱ្យជនជាតិខ្មែរមួយចំនួនអស់សេចក្តីសង្ឃឹម សុខចិត្តដេកគងថ្ងាស់យ៉ាងស្ងៀមស្ងាត់ រង់ចាំដែលខ្លួនត្រូវធ្វើដំណើរចាកលោកនេះទៅតាមយថាកម្ម ជាពិសេសជនចាស់ជរា ដែលពុំមានអ្វីអាង ក្រៅពីពោលពាក្យសន្ទឹមៗថា "ពាលអាងកាប់ ចាស់អាងស្លាប់ ក្មេងអាងយំ" តែប៉ុណ្ណោះ ។

ប៉ុន្តែសូមបញ្ជាក់ថា នៅក្នុងអរិយប្រទេស ជនចាស់ជរា គឺជាគ្រាប់ដុំពេជ្រមួយគ្រាប់ បានច្នៃរួចស្រេច មានតម្លៃខ្ពស់ណាស់ សំរាប់ជួយការពារទ្រទ្រង់ប្រទេស និងសង្គមជាតិទាំងមូលឱ្យបានទៅដល់វឌ្ឍនភាពគ្រប់វិស័យ សុខសន្តិភាព និងសុវត្ថិភាព ក្នុងជីវិតពេញលក្ខណៈជាមនុស្សជាតិ ទាំងក្នុងពេលមានជីវិតរស់នៅ ទាំងក្នុងពេលចូលមរណកាលទៅវិញ ៕

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**

- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆាសាច់គោ
- មីកន្ទាំងឆាគ្រឿងសមុទ្រ
- បាយឆាគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**

- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់សារជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# PHILLY FOR FAMILY UNITY AND DEPORTATION REFORM



By Mia-lia Kernan

•••អ្នកមានទោសខ្មែរ ២៥០នាក់ ហើយដែលបានត្រូវបញ្ជូនឱ្យត្រឡប់ទៅកម្ពុជាវិញ ហើយនៅសល់ ១៥០០នាក់ទៀត ដែលត្រៀមនឹងបញ្ជូនជាបន្តបន្ទាប់ ដែលជាទង្វើគ្មានសីលធម៌ចំពោះអ្នកដែលបំពេញទោសចប់សព្វគ្រប់ កំពុងរស់នៅយ៉ាងសុខសាន្តជាមួយក្រុមគ្រួសារដ៏កំសត់ ដែលបានទទួលការព្រាត់ប្រាស់ម្តងរួចមកហើយ ។

សមាគមខ្មែរ សហគមន៍ស្ប៉ានីស និងជនជាតិភាគតិចមួយចំនួន បាននាំយកហត្ថលេខាច្រើនពាន់នាក់ ដែលគាំទ្រចលនាបង្រួបបង្រួមគ្រួសារ និងប្រឆាំងការនិរទេសខ្លួន បានទទួលការគាំទ្រពីបំណងកែច្បាប់និរទេសខ្លួននេះ ឈ្មោះ HR 4321 ពីព្រឹទ្ធសភា បុបប្រាឌី កាលពីថ្ងៃទី២ ខែកុម្ភៈ កន្លងទៅ ហើយមានបំណងបន្តសកម្មភាពរបស់ខ្លួនទៅទាក់ទងព្រឹទ្ធសមាជិកអ្នកធ្វើច្បាប់នៅសហរដ្ឋអាមេរិកឯទៀតៗ រហូតដល់បានសម្រេចជោគជ័យ ។ មាលា សូមរាយការណ៍ជាភាសាអង់គ្លេសដូចតទៅ:

On Tuesday February 2nd, 2010, community members, advocates and religious leaders met with the District Director of U.S. Representative Bob Brady's office at 1907 South Broad Street, to urge the Congressman to co-sponsor HR 4321, an immigration reform bill which would help families in our community who are facing the deportation of a loved one. Representative Brady's District includes much of the Cambodian community in South Philadelphia on the east side of Broad Street. Community members told their stories of living with the impending orders of removal that would eventually separate them from someone they love. They told stories of family members who have already been forcibly removed, separated from their loved ones and have had to start a new life in Cambodia.

Our community suffers through the continuous deportation of fathers, sons, uncles, mothers, daughters, aunts, grandparents, and friends. Since Cambodia signed the Memorandum of Understanding with the United States in 2002 to accept deportees




back to Cambodia, the United States has deported over 250 people, and over 1500 Cambodian-Americans are awaiting deportation around the country, and dozens of those people are from Philadelphia. When will it stop?

As the deportation law stands now, no leniency is given to folks who came to the US under refugee status - no consideration is given to the fact that individuals are being deported to a country they once fled. As the law stands now, immigration judges are not given the opportunity to hear the individual circumstances of each case - no consideration can be given to the effects deportation of a parent will have on children. HR 4321 would prevent the deportation of Cambodian-Americans who came to the United States as refugees before the age of 12. It would also allow for an individualized hearing, and give immigration judges more room to consider the best interest of a US citizen child before ordering his/her parent deported. Many organizations in Washington DC fought hard to ensure that these parameters would be included in HR 4321, namely the Southeast Asian Resource Action Center (SEARAC).

After Christmas 2009, a petition was released among our community, and due to the efforts of inspiring community members, nearly 500 signatures were collected. This petition was brought to Representative Brady's office on February 2, along with over 1,000 signatures collected by Latino organizations within their communities. Together this diverse group of community members from South Philly handed over their collaborative petitions and asked for Representative Brady to serve his constituents by co-sponsoring HR 4321 - and he did...that very same morning!

However, the work is not over. In Philadelphia, we now have two US Representatives who have co-sponsored the bill - Representative Bob Brady and Representative Chaka Fattah. But we still have two US Representatives in Philadelphia who have yet to co-sponsor - Representative Allyson Schwartz and Representative Patrick Murphy - both of whom will be much more difficult to convince, so please keep signing the online petition: http://www.petitiononline.com/fam2010/ For more resources, please contact Mia-lia at CAGP. mialiabk@gmail.com 215 313 9298.




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន

**USA**
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

**Cambodia Office: Victory Travel (Skin Belle)**
**No 57B, Eo Street 205 Touls Svay Prey 2.**
**Phnom Penh, Cambodia.**
**Ms. Chenda: 023-221069 * 012-851575**
**Or Mr. Sin Po: 012 429407 * 011-541111.**
SERVING SINGAPOR, EVA AIR, KOREAN AIRLINES, MALAYSIA etc...

**New World Travel II**
ញូវើលត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036




ដោយ : គឹម ភឿន (តពីលេខមុន)

កុំយំឱ្យសោះពៅពន្លក! បងពុំអាចមកជូតនេត្រា
ឱ្យអូនបានទេណាជីវ៉ា ទប់ទឹកនេត្រាកុំឱ្យហូរ ។
រទេះសេះមួយអូសម្ឈូសបង កាត់ផ្លូវដែលយើងធ្លាប់សច្ចារ
ក្រោមស្លឹកឈើជ្រុះទឹកនេត្រា... បានជនហូរហៀរលើថ្ពាល់ស្រី ។
សេះអូសម្ឈូសបងកាត់វិថី កាត់វត្តមហាមន្ត្រី និងលង្កា
បុទុមធម្មយុត និងឧណ្ណាឡោម នៅជិតក្បែរផ្សារកណ្ដាល ។
ខ្លងខែកខំស្រែកប្រាយប្រាប់ថា រូបបងសង្ខារបែកឆ្ងាយហើយ
ទៅតាមទឹកដីមិនវិលឡើយ ស្នេហ៍អើយមាសស្នេហ៍នាងកុំយំ ។
គេនាំម្ឈូសបងទៅបញ្ចុះ វាលបាឆានោះទីសែនស្ងប់
ឱ្យបងគេងលក់ និងបានស្ដាប់ លាពុំត្រឡប់រាប់រយឆ្នាំ ។
សុំអូនកុំមកជិតផ្នូរបង ទឹកភ្នែកនិងភួងបុប្ផស្រស់
ធូបបីសរសៃនិងផ្សែងនោះ ឱ្យបងអាឡោះអាឡៃស្រី ។
ទុកបងសម្ងំគេងក្រោមផ្នូរ អាធ្រាត្រយប់យូរស្ដាប់សត្វយំ
ច័ន្ទខាងរនោច មេឃស្រទំ ព្ធចង្រិតយំពាសពេញព្រៃ ។
កុំយំ! កុំព្រួយ! កុំស្រណោះ! កុំទឹកភ្នែកឱ្យសោះណាំពៅស្រី
បងមិនអីទេកល្យាណី សូមឱ្យពៅស្រីនៅបានសុខ ។
ធ្វើម្ដេចកម្មយើងពុំជួបជូន អូនអើយមាសស្ងួនចាំជាតិក្រោយ
ទឹកដីគ្រោះថ្នាក់ស្រែកដង្ហោយ ស៊ូស្លាប់មិនឱ្យខ្មាំងយកបាន ។
រូបបងស្លាប់ហើយអស់ផុតទុក្ខ ពីនេះទៅមុខមានតែពៅ
សូមអូនខំទ្រាំស៊ូរស់នៅ បង្រៀនប្រដៅកូនចៅខ្មែរ ។
ឱ្យគ្នាបានស្គាល់អ្វីហៅជាតិ កុំឱ្យឃ្លាងឃ្លាតពីមាតា
បំរើប្តូរផ្ដាច់ជាតិសាសនា ជាតិសាសន៍ខេមរាឱ្យគង់វង្ស ។
មើលទៅជាតិយើងមានគ្រោះភ័យ វិនាសអន្តរាយជិតបង្ហើយ
មនុស្សចាស់ជាន់មុនតិចណាស់ហើយ ដែលចេះសោកស្ដាយរឿងទឹកដី ។
សូមបណ្ដុះក្មេងជំនាន់នេះ ឱ្យចេះត្រិះរិះពិចារណា
ស្រឡាញ់ទឹកដីកេរ្ដិ៍ជូនតា រក្សាការពារឱ្យគង់វង្ស ។
បើអប់រំក្មេងជំនាន់នេះ គ្មានអីប្លែកសោះពីបុរាណ
មុកតែនាំគ្នាដើរជាន់ដាន រលាយភូមិឋានអស់គ្មានសល់ ។
ក្រសួងអប់រំជាតិទាំងមូល ទំពាំងជាស្នូលជាតិខេមរា
អប់រំប្រវត្តិសាស្ត្ររបៀបណា ទើបគ្មានចងចារយល់ដឹងអី ។
ជាតិនឹងរលាយព្រោះអវិជ្ជា ប្រវត្តិសាស្ត្រវិទ្យាគ្មានចេះចាំ
ភូមិសាស្ត្រមិនហ៊ានថាឱ្យចំ អនាគតដឹកនាំកម្ពុជា ។
ត្រូវតែហ៊ានប្រាប់ក្មេងរឿងពិត ត្រូវប្ដូរគំនិតចាស់គំរិល
លាក់លៀមកំហុសអតីតកាល ព្រោះខ្លាចក្មេងដៀលថាខ្លួនអន់ ។
ហេតុនេះមហានគរពីបុរាណ ត្រូវរលាយប្រាណពីត្រឹមណា
អ្នកណាលក់ជាតិក្បត់ខេមរា អ្នកណាហានក្លាស្រោចស្រង់ជាតិ? ។
បើមិនកែប្រែមុខតែស្លាប់ ព្រោះក្មេងពុំគាប់ចេះដឹងអី
រៀនសូត្រចេះចប់ធ្វើមន្ត្រី នេះហើយស្មារតីអ្នកអប់រំ ។
បើបាត់ទឹកដីអស់ទៅហើយ ម៉ែអើយមន្ត្រីទៅទីណា
"ខ្ញុំម៉ែថើយអើយ" ជាតិខេមរា "តាវជាញ់ចេតចាបីហេតរ៉ូយ" ។
(ចុយម៉ាយអាជាតិខេមរាអើយ! អញវាយងាប់ឌឹងឯងអស់ហើយ!)

អូនសំឡាញ់! សុំទោសអូនដោយស្មោះអស់ពីដួងចិត្ត មិនគួរបងបណ្ដោយឱ្យមនោសញ្ចេតនាដឹកនាំអារម្មណ៍បងសរសេរនូវវេទនារម្មណ៍ទាំងនេះជូនអូនសោះតែនេះជាវេទនារម្មណ៍ពិតមិនមានបន្ថែមនិងគ្មានបន្ថយឡើយ នៅក្នុងពេលនេះ ។ បងហាក់ដូចអស់សង្ឃឹម ឬអស់រំពឹងទៅលើថ្នាក់លើក្នុងការដឹកនាំ ទៅរកសន្តិភាពសម្រាប់ប្រទេសជាតិយើងព្រោះឃើញតែស្រវ៉ារេចស្រវ៉ាខ្ចប់ ។ ហាក់ដូចសង្គ្រាមពេលនេះជាឱកាសឱ្យលោកធ្វើមានធ្វើបាន ។ លុយកាក់ ទ្រព្យសម្បត្តិ សម្ភារៈជាគោលដៅទីមួយសម្រាប់អស់លោក ។ អស់លោកហាក់ដូចជា គ្មានដែលគិតថាអនាគតនឹងទៅជាយ៉ាងណាប្រសិនបើចាញ់សង្គ្រាម... ហ៊ានលុយរៀលទៅហើយ តើឱ្យរំពឹងលើអីទៀត ?

អូនសំឡាញ់! មិនដែលបានសរសេរសំបុត្រជូនអូនសោះ ស្រាប់តែចាប់សរសេរភ្លាម ចាប់យកតែរឿងពិតគ្រោតគ្រាតមកសរសេរជូនអូនជ្រាបទៅវិញ ។ ចាំបងអានអស់សំបុត្ររបស់អូនទាំងប្រាំនេះសិន តើអូនសរសេរអ្វីមកបងខ្លះ បងនឹងសរសេរជូនអូនទៀត ហើយសរសេរពីរឿងពិតមួយដ៏ជាទីសប្បាយរីករាយ និងសង្ឃឹមសម្រាប់អនាគតយើង ។

ដោយក្ដីនឹករលឹកយ៉ាងខ្លាំងពីបងនាសមរភូមិជួរមុខនៃមាតុភូមិ :

**គឹមវិរៈ**

***(សូមរង់ចាំអានភាគបន្តនៅលេខក្រោយ)***

*ឆ្លើយតបសំនួរមិត្តអ្នកអាន*

# Three Cups of Tea
# ទឹកតែ៣ពែង

(តពីលេខមុន)



**ដោយ : គឹមភឿន**

•••ក្រោយពីការសន្យារួចហើយ គ្រែគ ត្រឡប់មកសហរដ្ឋអាមេរិកវិញជាមួយនឹងប្រាក់បន្តិចបន្តួច សល់ជាប់នឹងបាតហោប៉ៅ បាត់អស់ការងារសម្រាប់ការរស់នៅនៃជីវិត បាត់រហូតដល់សង្សាម្ដងមួយ ហើយម្ដងមួយទៀត ព្រោះគ្រែគ គិតតែពីស្វែងរកជំនួយ ដើម្បីកសាងសាលារៀនមួយខ្ទងតាមពាក្យសន្យា ។ តែពុំអស់សង្ឃឹម ហើយបោះបង់ចោលពាក្យសន្យាឡើយ រហូតដល់ក្រោយមកមួយទសវត្ស គ្រែគ សាងសង់បានរហូតដល់ជាង ៦០ សាលារៀន នៅក្នុងទឹកដីប៉ាគីស្ថាន រាលដាលចូលដល់រហូតក្នុងទឹកដីអាហ្គានីស្ថានទៀត! ទោះមានការនឿយហត់ លំបាកលំបិនរហូតដល់ស្រក់ទឹកភ្នែកក៏ដោយ ក៏បុរសដ៏ក្លាហាននេះ ពុំបោះបង់ចោលនូវអំពើកុសលរបស់ខ្លួនឡើយ ។ មានពេលខ្លះទទួលបានសំបុត្រអកុសលពីជនជាតិអាមេរិកាំងខ្លួនឯងចោទថា គាត់បានជួយដល់ខ្មាំងប្រឆាំងប្រទេសខ្លួនឯង ហើយគេប៉ុនប៉ងនឹងសម្លាប់ មានពេលខ្លះទៀត គ្រែគ ត្រូវពួកម៉ាហ្វៀជួញគ្រឿងញៀនចាប់ទុកជាចំណាប់ខ្មាំង មានពេលខ្លះរត់គេចចេញពីមុខសិក ដែលកងទ័ពកំពុងច្បាំងគ្នានៅចំពាក់កណ្ដាលផ្លូវ ដែលគាត់កំពុងធ្វើដំណើរបំពេញភារកិច្ចរបស់ខ្លួនព្រលឹងនៅចុងសក់! ។ គាត់បានចាប់ផ្ដើមធ្វើដំណើរពីចំណុចមួយ ដែលសារព័ត៌មានអាមេរិកាំងទាំងឡាយរិះគន់ថា មិនត្រឹមត្រូវរហូតដល់សារព័ត៌មានទាំងនោះបែរមកពោលសរសើរថាត្រឹមត្រូវវិញ រហូតដល់អស់លោកព្រឹទ្ធសភាអាមេរិកាំងគាំទ្រកិច្ចការជំនួយសាងសង់របស់លោកនៅប្រទេសប៉ាគីស្ថាន និងអាហ្គានីស្ថាន ដែលជាប្រទេសមិនសូវបានរាប់អានថាជាមិត្តនោះទៅវិញ ។ លោកបានទាំងហ៊ានរិះគន់ដល់នយោបាយរបស់លោកប្រធានាធិបតី ប៊ូស ចំពោះប្រទេសទាំងពីរនេះផងរហូតដល់លោកប្រធានាធិបតី បានយល់ស្របផ្នែកជំនួយក្នុងវិស័យអប់រំនៃប្រទេសទាំងពីរនេះថាជាការចាំបាច់ ។

បុរសដ៏អស្ចារ្យ បានត្រូវបាត់បង់អស់ការងារបាត់អស់សង្សាជាទីស្រឡាញ់សម្រាប់កំដរជីវិតគ្មានសល់ដល់មួយដុល្លារក្នុងបាតហោប៉ៅ លក់អស់ទាំងរថយន្តជាមរតកចុងក្រោយរបស់ខ្លួន ព្រោះតែបុព្វហេតុកសាងសាលារៀនមួយជូនកុមារាកុមារីដ៏កំសត់របស់ភូមិកហ្វេ ។ តើ គ្រែគ ធ្វើយ៉ាងណាទើបអាចកសាងសាលារៀនបាន មិនគ្រាន់តែមួយ តែរហូតដល់ជាងហុកសិប និងសមិទ្ធិផលផ្សេងៗទៀត ដូចជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលមុខរបរសំរាប់នារីភេទ និងជាទីប្រជុំរបស់ពួកនារីផង ព្រោះនៅក្នុងប្រទេសមូសលីមស្រីៗមិនអាចមានលទ្ធភាពទៅរៀនសូត្រ និងជួបប្រជុំគ្នាបានទេ ។ បុរស គ្រែគ ពិតជាបុរសអស្ចារ្យ បានបើកទំព័រប្រវត្តិសាស្ត្រនៃយុគសម័យថ្មីមួយសម្រាប់ប្រទេសប៉ាគីស្ថាន និងអាហ្គានីស្ថាន ។

នេះជាបដិវត្តន៍មួយដែលបានកែប្រែទំលាប់ធ្លាប់មានមករាប់ពាន់ឆ្នាំមកហើយ ដោយគ្មានចំណាយគ្រាប់កាំភ្លើងអស់មួយគ្រាប់ណាឡើយ តែចំណាយនូវមេត្តា, ករុណា, សុឆន្ទៈ, សុចរិតធម៌ និងការលះបង់ខ្ពស់... ជាពុទ្ធសាសនិកជនគួរចោលភ្នែកសម្លឹងគាត់ និងពិចារណាសម្លឹងមកខ្លួនឯង ដែលគោរពនិងស្រឡាញ់ ព្រះសមណគោត្តមបរមគ្រូ ថាតើគួរយើងបង្រៀន គ្រែគ ពីមេត្តា, ករុណា... ការលះបង់ខ្ពស់ជូនគាត់ ឬរៀនអំពីគាត់មកវិញ? ជាខ្មែរ ប្រទេសខ្មែរកំពុងរង់ចាំមនុស្សប្រភេទ គ្រែគ នេះយ៉ាងទទូចបំផុត មិនមែនសម្រាប់យកទៅជួយប្រទេសដទៃឡើយ តែសម្រាប់ជួយខ្មែរ ប្រទេសខ្មែរខ្លួនឯង ព្រោះនៅទីនោះ អ្នកដឹកនាំសឹងតែបាត់អស់នូវតម្លៃនៃដំបូន្មានរបស់ព្រះសមណគោត្តមអស់ហើយ... ដើម្បីយល់ច្បាស់ថា បុរសអស្ចារ្យនេះជាអ្នកណា មកពីណា បានជាគាត់ដើរតាមមាគ៌ានៃព្រះសមណគោត្តមដោយខ្លួនគាត់មិនមែនជាសិស្សគុណរបស់ព្រះអង្គផង?! យើងនាំគ្នាស្វែងយល់ពីគ្រួសារ ពីខ្លួនគាត់ផ្ទាល់ ដើម្បីហេតុផលនៃអំពើកុសលរបស់គាត់ និងភាពអំណត់តស៊ូរបស់គាត់ ដែលមិនសូវធ្លាប់ឃើញមានក្នុងបុរសដទៃនៃមនុស្សជាតិ ។ យើងគួរអានសេចក្ដីផ្ដើមទាំងស្រុងដែលលោក គ្រែគ សរសេរ ផ្ទាល់ដៃទៅកាន់ការផ្សាយនៃក្រុមហ៊ុន The Young Reader's Edition បានជ្រើសរើសយករឿង "ទឹកតែ៣ពែង" នេះមកបោះពុម្ពផ្សាយ និងទៅកាន់សិស្សានុសិស្សទាំងឡាយដែលកំពុងអានសៀវភៅនេះដូចតទៅ:

អាស សាឡាមអាឡៃគម! នេះជាភាសារបស់សាសនិកជនអ៊ីស្លាមជាង១លាន៣សែននាក់លើពិភពលោក បានប្រើទុកសម្រាប់ស្វាគមន៍គ្នា និងសំដែងក្ដីប្រាថ្នារបស់គេពេលជួបគ្នា ឬចាប់ផ្ដើមថ្លែងសុន្ទរកថាអ្វីមួយ ហើយមានន័យថា "សូមឱ្យសន្តិភាពចូលមានដល់អ្នក" ដូចគ្នានឹងពុទ្ធពរខាងពុទ្ធសាសនិកជនថា "សូមឱ្យក្ដីស្ងប់ចូលមានដល់អ្នក" យ៉ាងនោះដែរ) ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការផ្សាយរបស់ក្រុម The Young Reader Edition ។ ខ្ញុំសង្ឃឹមថា រឿងរបស់ខ្ញុំបានធ្វើឱ្យលោកចាប់អារម្មណ៍ ហើយវាជាការដក់ចិត្តដក់អារម្មណ៍ក្នុងការអាន និងសិក្សាពីក្មេងៗទាំងឡាយដូចរូបអ្នកដែលកំពុងរស់នៅក្នុងប្រទេសផ្សេងៗ មានអរិយធម៌ ជំនឿ, ប្រពៃណីផ្សេងៗគ្នា ។

ការអាន ភាពចេះអាន និងសរសេរមានភាពសំខាន់ណាស់សំរាប់ខ្ញុំ និងគ្រួសាររបស់ខ្ញុំ ។ ពេលខ្ញុំទើបតែធំឡើងនៅទ្វីបអាហ្វ្រិក ឪពុកម្ដាយខ្ញុំតែងអានរឿងឱ្យខ្ញុំ និងប្អូនស្រីខ្ញុំស្ដាប់មុនពេលគេងតាំងតែពីពេលមិនទាន់ចេះដើរម្ល៉េះ ។

**(សូមរង់ចាំអានភាគបន្តនៅលេខក្រោយ)**

# A.B.C MONEY TRANSACTION, INC

# ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |



សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

**8 locations to serve you in Virginia**

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**

◆4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**

◆ 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**

◆4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**

◆ 996 Dorchester Ave. Tel:617.825.9380

◆ 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**

◆ 2718 Nicollet Ave . S.- Ste. 102 B

◆ Tel : 612.871.4731

◆ 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**

◆ 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**

◆6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**

◆5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794

◆571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**

◆1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461

◆2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817

◆5302 E . Belknap St.- Ste.D6 . Tel : 817.831.4836

◆3538 W . Walnut St. Tel : 972.272.2253

◆11205 Bellaire Blvd . Tel : 281.561.6600

◆10909 Scarsdale Blvd . Tel : 281.481.2700

◆13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**

◆766 S.38th St,. Tel : 253.475.2847

◆3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776

Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាន់ថ្មីប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១៩ ខែកុម្ភៈ ឆ្នាំ២០១០

# Officials Urge Caution After Carjacking Rape

**By Neou Vannarin**
THE CAMBODIA DAILY

Officials yesterday said they were still investigating the kidnapping and rape of a 17-year-old student that took place earlier this week, but noted that people should take care not to put themselves in potentially dangerous situations.

Khuong Sreng, governor of Phnom Penh's Sen Sok district, said that by parking in a dark and largely deserted area, the victim—who was violently abducted on Sunday night and driven from the capital to Kompong Speu province where she was raped and then robbed while her 4-year-old-neice sat in the car—created an opportunity for the crime to occur.

"She parked the car in a dark place which was so far from others, and left the keys in the car because she wanted to listen to music while she was waiting," said Mr Sreng, adding that there are police stationed in Sen Sok district but that they cannot keep constant watch on every movement.

"I do not blame this on the victim," he said yesterday. "But the criminals are lying in wait in order to make any crime if there is an opportunity."

"I would like to call the people to be careful," he added.

San Arun, secretary of state at the Ministry of Women's Affairs, said yesterday that while she didn't know the details of the crime, it is important to stay vigilant.

"It is difficult to say it is her fault, but she should be careful with herself. Even myself, I lock the door, I try to be very careful," she said.

Kompong Speu provincial penal police chief Svay Yoeun said yesterday that police are working to track down the three suspects.

"We have some clues for the perpetrators. They are not local targets but outsiders," he said, declining to provide more detail on the confidential investigation.

Peanratha Manith, senior child rights monitor for Licadho, said yesterday that he had just received the case and was working on an investigation as well.

"The area is so quiet, which can provide lots of opportunity to commit the crime," he said. But, he added, "the victim is already suffering. If we put any blame on her it would make her feel like no one takes care of her."

*(Additional reporting by Abby Seiff)*

# ក្រុមមន្ត្រីទទូចឱ្យមានការប្រុងប្រយ័ត្ន ក្រោយពីមានករណីចាប់ពង្រត់និងរំលោភ

**ដោយ នៅ វណ្ណារិន**
THE CAMBODIA DAILY

កាលពីថ្ងៃព្រហស្បតិ៍ ក្រុមមន្ត្រីបាននិយាយថា ពួកគេនៅកំពុងស៊ើបអង្កេតការចាប់ពង្រត់និងរំលោភលើសិស្សអាយុ១៧ឆ្នាំម្នាក់ដែលបានកើតឡើងនៅដើមសប្តាហ៍នេះ ប៉ុន្តែបានកត់សម្គាល់ថា ប្រជាជនគួរតែប្រុងប្រយ័ត្នកុំបណ្តោយឱ្យខ្លួនឯងស្ថិតក្នុងស្ថានភាពដែលអាចមានគ្រោះថ្នាក់ ។

លោក ខួង ស្រេង អភិបាលខណ្ឌសែនសុខក្នុងទីក្រុងភ្នំពេញ បានមានប្រសាសន៍ថា ការចតយានយន្តនៅកន្លែងងងឹត និងស្ងាត់នោះ ជនរងគ្រោះ(ដែលត្រូវបានចាប់ពង្រត់ដោយហិង្សាកាលពីយប់ថ្ងៃអាទិត្យ ហើយយកតាមរថយន្តចេញពីរាជធានីទៅកាន់ខេត្តកំពង់ស្ពឺ ជាទីដែលនាងត្រូវបានរំលោភ ហើយប្លន់ ខណៈដែលក្មួយស្រីអាយុ៤ឆ្នាំរបស់នាងអង្គុយនៅក្នុងរថយន្តនោះ)បានធ្វើឱ្យមានឱកាសសម្រាប់បទល្មើសកើតឡើង ។

លោក ខួង ស្រេង បានមានប្រសាសន៍ថា "នាងបានចតរថយន្តនៅកន្លែងងងឹតដែលនៅឆ្ងាយពីគេយ៉ាងខ្លាំង ហើយបានទុកសោនៅក្នុងរថយន្តនោះ ដោយសារតែនាងចង់ស្តាប់ចម្រៀងខណៈដែលនាងកំពុងរង់ចាំ" ។ លោកបានមានប្រសាសន៍បន្ថែមថា មាននគរបាលឈរជើងនៅខណ្ឌសែនសុខ ប៉ុន្តែថា ពួកគេមិនអាចឃ្លាំមើលជាប្រចាំឱ្យបានគ្រប់ជ្រុងជ្រោយទេ ។

លោកបានមានប្រសាសន៍កាលពីម្សិលមិញថា "ខ្ញុំមិនបន្ទោសរឿងនេះលើជនរងគ្រោះទេ" ។ "ប៉ុន្តែឧក្រិដ្ឋជនរង់ចាំប្រព្រឹត្តបទល្មើស ប្រសិនបើមានឱកាស" ។ លោកបានមានប្រសាសន៍បន្ថែមថា "ខ្ញុំសូមអំពាវនាវឱ្យប្រជាជនមានការប្រុងប្រយ័ត្ន" ។

ខណៈដែលលោកស្រីមិនដឹងអំពីពត៌មានលំអិតនៃបទល្មើសនេះ លោកស្រី សាន អរុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារីបានមានប្រសាសន៍កាលពីម្សិលមិញថា ការរក្សាការប្រុងប្រយ័ត្នមានសារៈសំខាន់ណាស់ ។

លោកស្រីបានមានប្រសាសន៍ថា "វាមានការលំបាកក្នុងការនិយាយថា វាជាកំហុសរបស់នាង ប៉ុន្តែនាងគួរតែប្រយ័ត្នប្រយែងចំពោះខ្លួនឯង ។ សូម្បីតែខ្លួនខ្ញុំ ខ្ញុំចាក់សោទ្វារ ខ្ញុំព្យាយាមប្រុងប្រយ័ត្នណាស់" ។

លោក ស្វាយ យឿន ប្រធាននគរបាលព្រហ្មទណ្ឌខេត្តកំពង់ស្ពឺបានមានប្រសាសន៍កាលពីម្សិលមិញថា នគរបាលកំពុងតែធ្វើការដើម្បីតាមចាប់ខ្លួនជនសង្ស័យទាំង៣នាក់ ។

ដោយបដិសេធមិនផ្តល់ពត៌មានលំអិតបន្ថែមអំពីការស៊ើបអង្កេតសម្ងាត់នេះទេនោះ លោកបានមានប្រសាសន៍ថា "យើងមានតម្រុយមួយចំនួនអំពីជនល្មើស ។ ពួកគេមិនមែនជាគោលដៅក្នុងមូលដ្ឋានទេ ប៉ុន្តែជាអ្នកមកពីខាងក្រៅ" ។

លោក ភៀនរដ្ឋា ម៉ានិត អ្នកអង្កេតជាន់ខ្ពស់ផ្នែកសិទ្ធិកុមារនៅអង្គការលីកាដូបានមានប្រសាសន៍កាលពីម្សិលមិញថា លោកទើបតែទទួលបានសំណុំរឿងនេះ ហើយកំពុងតែធ្វើការស៊ើបអង្កេតដូចគ្នា ។

លោកបានមានប្រសាសន៍ថា "តំបន់នោះមានសភាពស្ងប់ស្ងាត់ណាស់ ដែលអាចផ្តល់ឱកាសជាច្រើនក្នុងការប្រព្រឹត្តបទល្មើស" ។ ប៉ុន្តែលោកបានមានប្រសាសន៍បន្ថែមថា "ជនរងគ្រោះកំពុងតែទទួលរងការប៉ះទង្គិចរួចទៅហើយ ។ ប្រសិនបើយើងបន្ទោសនាងទៀត វានឹងធ្វើឱ្យនាងគិតថា គ្មាននរណាម្នាក់យកចិត្តទុកដាក់លើរូបនាងទេ" ។ *(រាយការណ៍បន្ថែមដោយ Abby Seiff)* P

# New Rules Cut Into Profits, Boat Operators Say

**By Hul Reaksmey**
THE CAMBODIA DAILY

Boat operators expressed frustration yesterday over costly fees being charged by the newly formed Phnom Penh Tourist Water Association, which decided last month to charge $3 every time a boat departs from the new landing station near Daun Penh district's Street 94.

Operators say the PPTWA started to collect the money from Jan 18—a day after all tour boats were required to land at the new location—and the additional costs are deeply affecting their profit margins.

"I pay three dollars for every time my boat departs," said Nath Tha, 46, a boat operator and member of the PPTWA. "The association has not let us know about revenue and expenditure being made."

He said PPTWA should not be responsible for constructing a new dock for boat operators.

Hei Bavy, general director of Phnom Penh Autonomous Port, said the new dock would be built near where the government palace currently stands.

"We will have a meeting to discuss this matter next week," he said, adding who will foot the bill had yet to be decided.

Boat operators and port officials are still negotiating parking prices at the new docking area, with prices ranging from $10 for a small boat to $20 for a big boat per month.

Ms Tha added that since she started making payments to the PPTWA, she has seen no improvements to the dock, which operators say would be insufficient during the rainy season.

She said that PPTWA should pay for the new dock if they are going to continue taking $3 from boat operators every time they take customers on a trip.

Boat operators say they made more money before Jan 18, when their vessels were allowed to dock anywhere along the riverbank and tourists could choose which boat they wanted to take.

"Before, I could make $150 per day. Now I only make $50," said Nos Ibrahim, 65, an owner of two boats along the riverfront.

Yien Srey, 37, another boat owner, said: "To collect three dollars is too expensive. I have to be responsible for nine people in my family."

PPTWA Director Ly Puthy rejected the complaints yesterday, saying the association was in fact paying for a number of measures such as purchasing uniforms and walkie-talkies for staff members.

"We pay wages for our staff as well," he said.

# ក្រុមម្ចាស់ទូកនិយាយថា បទបញ្ជាថ្មីធ្វើឱ្យប្រាក់ចំណូលធ្លាក់ចុះ

**ដោយ ហ៊ុល រស្មី**
THE CAMBODIA DAILY

កាលពីម្សិលមិញ ក្រុមម្ចាស់ទូកបានសម្តែងការមិនសប្បាយចិត្តដោយសារការយកតម្លៃខ្ពស់ដោយសមាគមទេសចរណ៍តាមផ្លូវទឹកក្រុងភ្នំពេញដែលទើបត្រូវបានបង្កើតឡើងនាពេលថ្មីៗនេះ ហើយដែលបានសម្រេចកាលពីខែមុនយកថ្លៃ៣ដុល្លាររាល់ពេលមានការចេញទូកពីចំណតថ្មីក្បែរផ្លូវលេខ៩៤ ក្នុងខណ្ឌដូនពេញ ។

ក្រុមម្ចាស់ទូកបាននិយាយថា សមាគមទេសចរណ៍តាមផ្លូវទឹកក្រុងភ្នំពេញបានចាប់ផ្តើមយកប្រាក់ពីថ្ងៃទី១៨ ខែមករា គឺមួយថ្ងៃបន្ទាប់ពីបានតម្រូវឱ្យទូកទេសចរណ៍ទាំងអស់ទៅចតនៅទីតាំងថ្មីនេះ ហើយតម្លៃបន្ថែមនេះកំពុងប៉ះពាល់យ៉ាងខ្លាំងចំពោះប្រាក់ចំណូលរបស់ពួកគាត់ ។

អ្នកស្រី ណាត ថា អាយុ៤៦ ឆ្នាំ ជាម្ចាស់ទូកនិងជាសមាជិកម្នាក់នៃសមាគមទេសចរណ៍តាមផ្លូវទឹកក្រុងភ្នំពេញបាននិយាយថា "ខ្ញុំបង់ប្រាក់៣ដុល្លាររៀងរាល់ពេលដែលទូករបស់ខ្ញុំចេញ ។ សមាគមនេះមិនបានឱ្យយើងដឹងអំពីប្រាក់ចំណូលនិងចំណាយទេ" ។

អ្នកស្រី ណាត ថា បានបន្ថែមថា ចាប់តាំងពីអ្នកស្រីបានចាប់ផ្តើមបង់ប្រាក់ទៅឱ្យសមាគមទេសចរណ៍តាមផ្លូវទឹកក្រុងភ្នំពេញមក អ្នកស្រីមិនឃើញមានភាពប្រសើរឡើងណាមួយចំពោះចំណតទូកនេះទេ ដែលក្រុមម្ចាស់ទូកនិយាយថា នឹងមិនសមស្របអំឡុងរដូវវស្សាឡើយ ។ អ្នកស្រីបាននិយាយថា សមាគមទេសចរណ៍តាមផ្លូវទឹកក្រុងភ្នំពេញគួរបង់ថ្លៃចំណតថ្មីនេះ ប្រសិនបើពួកគេ

(តទៅទំព័រទី ១៣)

# ASIAN STUDENTS STAND UP AGAINST SCHOOL VIOLENCE

By Mia-lia Kernan

•••និស្សិតវិទ្យាល័យហ្វីឡាខាងត្បូង បន្តសកម្មភាពមិនពេញចិត្ត ចំពោះសន្តិសុខសម្រាប់សិស្សអាស៊ី នៅសាលារៀន នៅចំពោះគណៈ-កម្មាធិការសាលាក្រុងខាង ទំនាក់ទំនងមនុស្ស ហើយទាមទារឱ្យអាជ្ញាធរផ្លាស់ប្តូរនយោបាយបច្ចុប្បន្នឱ្យបានឆាប់រហ័ស ដើម្បីភាពកក់ក្តៅសម្រាប់សុវត្ថិភាពសិស្ស ។

សហគមន៍ខ្មែរក៏មានប្រវត្តិជួរចត់ដូចគ្នាច្រើនឆ្នាំនឹងនៅស្មើរតែគ្រប់សាលា ក៏ប៉ុន្តែអាណាព្យាបាលតិចតួចណាស់ ដែលហ៊ានរួមកម្លាំងគ្នា ការពារកូនចៅខ្លួនឱ្យបានស្វាហាប់ ។

ព្រឹត្តិការណ៍វាយតប់សិស្សអាស៊ីដោយសិស្សអាមេរិកាំងខ្មៅ កាលពីថ្ងៃទី ៣ ធ្នូ កន្លងទៅ បានធ្វើឱ្យមានការផ្ទុះចលនាសហគមន៍អាស៊ីទាំងមូលប្រឆាំងនឹងនយោបាយគ្មានប្រតិកម្មរបស់ក្រសួងអប់រំ "ស្គូល ឌីស្ទ្រីក" ។

មាតាបិតាពុំទាន់បានចេញ មកគាំទ្រកូនចៅខ្លួននៅឡើយ តែសមាគមនិងតំណាងវត្តព្រះពុទ្ធរង្សី ផ្លូវលេខ ៦ខាងត្បូង បានថ្លែងប្រាប់អាជ្ញាធរក្រុង ពីវិបត្តិនៃសហគមន៍ខ្មែរ ។ មាលា បាននាំសេចក្តីរាយការណ៍ជាភាសាអង់គ្លេសមកផ្សព្វផ្សាយជូនដូចតទៅ :

On December 3, 2009, 26 Asian students were attacked at South Philadelphia High School. This brought great concern and hurt to Asian communities of all kinds across Philadelphia. We will always be hurt when the misunderstanding of differences leads to violence, especially among our youth.

The students had various meetings with School District officials, they held press conferences, they organized a Community Speak out Vigil, and they testified at the School Reform Commission on December 9th, they met with members of the Mayor's Commission on Asian American Affairs and representatives from the Pennsylvania and Philadelphia Human Relations Commissions.

I, as a representative of CAGP, was deeply involved in the subsequent boycott of South Philadelphia High School led by over 80 students over the course of 8 school days. The students were not boycotting or demonizing the students who attacked them, but they were pointing responsibility




On Wednesday, December 13th, 2009, Students from South Philly High told the School Reform Commission what they think.

towards the system within the school and the School District that allowed the attacks to happen. Because there exists a systemic misunderstanding of cultural differences which caused the climate in the school to escalate to that point of random and racial violence.

Racially motivated violence against immigrants is prevalent all over the School District. Although the recent attacks were mainly perpetrated against Chinese and Vietnamese immigrant students, we must be aware that random attacks and violence are perpetrated against Cambodian immigrant students around the city as well. At the bottom of many incident reports I have seen, there lies a common theme, "I think they attacked because I am Asian."

Many folks believe this is caused by a misconception of language, as many students attacked in these cases are English Language Learners. In our schools there is little value of language, of learning languages, of hearing other languages being spoken, and often this systemic devaluing can lead to misunderstanding, and violence.

The students who boycotted South Philadelphia High School spent their time away from school coming to profound conclusions after sharing stories with each other and breaking down the roots of racism and bias violence. Their cause was to create a safe learning environment for all students at South Philadelphia High School, Asian, Asian-American, African-American, Latino, and Caucasian. The students discovered how they could approach the climate at their school in a progressive way, but they also knew that they needed the system to change for the benefit of all students in Philadelphia Public Schools.

The students did everything they could to get their thoughts on the table for the cause of creating safe schools. Eventually on Tuesday December 15th, they met with Superintendent Arlene Ackerman to voice their concerns, and after the meeting they declared the boycott suspended, and returned to school on Wednesday December 16th.

